**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ១៤១៥ ព.ណ. ចបព

ភ្នំពេញ, ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពីនីតិវិធីទូទាត់កម្រៃសេវាចុះបញ្ជីពាណិជ្ជកម្ម

នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម សូមជម្រាបជូន **លោក-លោកស្រី ម្ចាស់សហគ្រាស** និង **អភិបាលក្រុមហ៊ុន** មេត្តាជ្រាបជាព័ត៌មានថា ចំពោះការទូទាត់កម្រៃសេវាលើការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ការកែប្រែព័ត៌មានផ្សេងៗរបស់ក្រុមហ៊ុន និងការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តកម្ម **លោក-លោកស្រី** អាចធ្វើការទូទាត់កម្រៃសេវាបានតាមមធ្យោបាយពីរប្រភេទរួមមាន ការទូទាត់តាមប្រព័ន្ធស្វ័យប្រវត្តកម្ម (Online) និងការទូទាត់ដោយផ្ទាល់តាមរយៈដៃគូធនាគារ (Offline) ដូចធ្លាប់បានជូនដំណឹងតាមរយៈប្រកាសលេខ ២១៣ព.ណ ចបព. ប្រក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម។

១. ការទូទាត់តាមប្រព័ន្ធស្វ័យប្រវត្តកម្ម (Online) លោក-លោកស្រី អាចធ្វើការទូទាត់បានតាមរយៈប្រព័ន្ធទូទាត់ប្រាក់ Online របស់ធនាគារ អេស៊ីលីដា (ACLEDA BANK)។

**នីតិវិធីទូទាត់ Online** លោក-លោកស្រី ត្រូវមានគណនីធនាគារអេស៊ីលីដា ដើម្បីធ្វើការទូទាត់តាម Online ដោយមិនចាំបាច់មកកាន់នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុនៅក្រសួងពាណិជ្ជកម្មដើម្បីធ្វើការផ្ទៀងផ្ទាត់នោះទេ។

២. ការទូទាត់ដោយផ្ទាល់តាមរយៈដៃគូធនាគារ (Offline)

លោក-លោកស្រី អាចធ្វើការទូទាត់ប្រាក់បានតាមលេខគណនីរបស់ក្រសួងពាណិជ្ជកម្មនៅធនាគារណាមួយដូចខាងក្រោម៖

- ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB)
  - KHR: 010-01-290-000094-0
  - USD: 010-30-063-000937-8
- ធនាគារកាណាឌីយ៉ា (CANADIA BANK)
  - KHR: 001-000-333-88-22
  - USD: 001-000-333-55-88
- ធនាគារ អេស៊ីលីដា (ACLEDA BANK)
  - KHR: 0001-02-076702-27
  - USD: 0001-02-076702-18

**នីតិវិធីទូទាត់ Offline**

**ជំហ៊ានទី១៖** បំពេញបែបបទក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មរហូតដល់ទំព័របង់កម្រៃសេវា។

**ជំហ៊ានទី២៖** Print Screen ទំព័របង់កម្រៃសេវាដើម្បីធ្វើជាឯកសារយោងទៅធនាគារណាមួយខាងលើ។

**ជំហ៊ានទី៣៖** បន្ទាប់ពីធ្វើការបង់កម្រៃសេវានៅធនាគាររួចរាល់ លោក-លោកស្រី ត្រូវយកវិក័យបត្រទូទាត់ប្រាក់ (Bank Receipt) ពីធនាគារមកកាន់នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ដែលមានទីតាំងនៅក្រសួងពាណិជ្ជកម្មជាន់ផ្ទាល់ដីដើម្បីធ្វើការផ្ទៀងផ្ទាត់។

**ជំហ៊ានទី៤៖** បន្ទាប់ពីធ្វើការផ្ទៀងផ្ទាត់រួចរាល់ លោក-លោកស្រី ចុចលើទំព័រក្រុមហ៊ុន (Company Profile) ម្តងទៀតដើម្បីដាក់ស្នើតាមប្រព័ន្ធស្វ័យប្រវត្តកម្ម (Online)។

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
*Phone/Facsimile: (855)-23 866 469*